# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...១០៧...អនក្រ

## សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការចំរុះអន្តរក្រសួងចុះពិនិត្យស្ថានភាពជាក់ស្តែង នៃផ្ទៃដីរបស់ក្រុមហ៊ុនវិនិយោគនីមួយៗនៅខេត្តមណ្ឌលគិរី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- ពិនិត្យការចាំបាច់របស់រាជរដ្ឋាភិបាល

## <u>សំរេច</u>

**<u>ប្រការ១</u>** : បង្កើតគណៈកម្មការអន្តរក្រសួងដើម្បីចុះពិនិត្យសកម្មភាពជាក់ស្តែងនៃផ្ទៃដីដែលបានផ្តល់ជូនក្រុមហ៊ុនវិនិយោគនីមួយៗនៅខេត្តមណ្ឌលគិរី ដូចមានសមាសភាពខាងក្រោម :

១- ឯកឧត្តម **នុត សាររាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាប្រធាន

២- ឯកឧត្តម **អ៊ិត ណូឌី** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអនុប្រធាន

៣- ឯកឧត្តម **គុល វីរក្ស** អគ្គាធិការរង ក្រសួងមហាផ្ទៃ ជាសមាជិក

៤- ឯកឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី** ទីប្រឹក្សាឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន ជាសមាជិក

៥- លោក **នុត ពុធដារ៉ា** អគ្គនាយករងរដ្ឋបាល ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ជាសមាជិក

៦- អ្នកស្រី ង៉ូ សុខដាវី ប្រធាននាយកដ្ឋាន ក្រសួងបរិស្ថាន ជាសមាជិក

៧- លោក យស មុនីរ៉ាត់ អនុប្រធាននាយកដ្ឋាន ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ជាសមាជិក

**ប្រការ២** : គណៈកម្មការនេះមានភារកិច្ច ÷

- សហការជាមួយអាជ្ញាធរដែនដីគ្រប់ថ្នាក់ដែលពាក់ព័ន្ធ ដើម្បីចុះពិនិតស្រាវជ្រាវស្ថានភាពជាក់ស្តែងនៃផ្ទៃដីដែលបានផ្តល់ជូនក្រុមហ៊ុននីមួយៗហើយត្រួតជាន់គ្នារវាងក្រុមហ៊ុនមួយ និងក្រុមហ៊ុនមួយទៀត ឬ ត្រួតជាន់លើដីប្រជាពលរដ្ឋ ឬ ត្រួតជាន់លើដីសម្បទានបំរុងទុក ឬ ត្រួតជាន់លើដីព្រៃជំរកសត្វនៅក្នុងខេត្តមណ្ឌលគីរី ។
- ពិនិត្យលក្ខណៈបច្ចេកទេសនៃការរុករានដី និង ការដាំដុះកូនឈើដែលត្រូវធ្វើវិនិយោគ ។
- ប្រមូលឯកសារសំខាន់ៗ និងពត៌មានពិតជាក់ស្តែង ដើម្បីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ពិនិត្យសំរេច ។

**ប្រការ៣** : គណៈកម្មការចំរុះអន្តរក្រសួងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ក្នុងករណីចាំបាច់ ។

**ប្រការ៤** : សមាជិកទាំងអស់របស់គណៈកម្មការត្រូវចូលរួមប្រជុំ និង ចុះបំពេញការងារតាមការអញ្ជើញរបស់ប្រធាន ។ ក្នុងករណីតំណាងក្រសួងណាម្នាក់មានធុរៈមិនអាចបំពេញការងាររបស់ខ្លួនបាន ក្រសួងនោះត្រូវចាត់តាំងតំណាងម្នាក់ទៀតជំនួស ។

**ប្រការ៥** : មធ្យោបាយធ្វើដំណើរ សំភារៈ និង ថវិកាចំណាយផ្សេងៗអាស្រ័យដោយសាម៉ីក្រសួងជាអ្នកទទួលបន្ទុកដោះស្រាយរៀងៗខ្លួន ។

**ប្រការ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីបណ្តាក្រសួងពាក់ព័ន្ធ និងឯកឧត្តម អស់លោក ដូចមានឈ្មោះក្នុងប្រការ១មានភារកិច្ចទទួលអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រីស្តីទី**

**ស ខេង**

**ចំលងជូន** :

- ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា
- ខុទ្ទកាល័យសម្តេចក្រុមព្រះប្រធានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

"ដើម្បីជូននិងថ្វាយជ្រាប"

- ដូចប្រការ១និងប្រការ៦

"ដើម្បីអនុវត្ត"

- ឯកសារ - កាលប្បវត្តិ .